**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៣០៧ សណន.កសក

# សារាចរណែនាំ
# ស្តីពី
# វិធានការទប់ស្កាត់ បង្ការការខូចខាតដោយគ្រោះទឹកជំនន់ ទឹកភ្លៀងរដូវវស្សា ឆ្នាំ២០១៨

ថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសង្កេតឃើញថាមានភ្លៀងធ្លាក់ជាបន្តបន្ទាប់នៅទូទាំងប្រទេស ដែលអាចធ្វើឱ្យតំបន់មួយចំនួនទទួលរងនូវបាតុភាពគ្រោះធម្មជាតិបង្កឡើងដោយទឹកជំនន់ទឹកភ្លៀង និងទឹកជំនន់ទឹកទន្លេមេគង្គ។ ស្ថានភាពនេះបង្កឱ្យមានការខូចខាតជាយថាហេតុដល់ដំណាំកសិកម្ម ពិសេសដំណាំស្រូវ ព្រមទាំងការបាត់បង់ដល់អាយុជីវិតសត្វពាហនៈ។

ដើម្បីត្រៀមលក្ខណៈជួយសង្គ្រោះផលដំណាំរដូវវស្សា និងសត្វពាហនៈក្នុងពេលមានទឹកជំនន់នោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់គ្រប់អង្គភាពបច្ចេកទេសក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់អនុវត្តនូវវិធានការចាំបាច់ និងបន្ទាន់មួយចំនួនដូចខាងក្រោម៖

- ត្រូវតាមដានជាប្រចាំនូវស្ថានភាពទឹកជំនន់ ត្រៀមលក្ខណៈសង្គ្រោះបន្ទាន់ វាយតម្លៃផលប៉ះពាល់ និងការខូចខាតជាបណ្តើរៗ ដើម្បីទទួលបានតួលេខពិតប្រាកដ ដោយក្តាប់ឱ្យបានទីតាំង និងស្ថានភាពភូមិសាស្ត្រដែលមានលទ្ធភាពអាចស្តារនូវការខូចខាតបាន
- ត្រូវសហការយ៉ាងជិតស្និទ្ធិជាមួយអាជ្ញាធរមានសមត្ថកិច្ច ពិសេសមន្ទីរធនធានទឹក និងឧតុនិយមរាជធានី ខេត្ត ដើម្បីចាត់វិធានការបញ្ចៀស បង្ការ និងទប់ស្កាត់ការខូតខាតដែលបណ្តាលមកពីគ្រោះទឹកជំនន់តាមលទ្ធភាពជាក់ស្តែង
- ត្រូវពិនិត្យលទ្ធភាព និងត្រៀមលក្ខណៈផ្តល់ស្រូវពូជ ព្រមទាំងពូជដំណាំផ្សេងៗសម្រាប់កិច្ចអន្តរាគមន៍ស្តារការខូចខាតឡើងវិញនាពេលខាងមុខ
- ត្រៀមរៀបចំសកម្មភាពធ្វើអន្តរាគមន៍ និងចាត់មន្ត្រីជំនាញឱ្យត្រៀមប្រចាំការនៅកន្លែងទីទួលសុវត្ថិភាព ដើម្បីពិនិត្យសុខភាពសត្វ សង្គ្រោះសត្វ និងចាត់វិធានការបសុព្យាបាល
- សម្របសម្រួលកិច្ចសហការជាមួយភាគីពាក់ព័ន្ធក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីសហការធ្វើអន្តរាគមន៍ធានាបង្ការ ការពារជំងឺសត្វ និងការ ផ្តល់ចំណីសត្វ
- ត្រៀមថ្នាំការពារ ព្យាបាល សម្ភារបសុព្យាបាលឱ្យបានគ្រប់គ្រាន់ ចំណីសត្វ និងត្រៀមទីទួលខ្ពស់មិនលិចទឹក ដើម្បីជម្លៀសសត្វនៅពេលមានទឹកជំនន់មកដល់
- ត្រូវអប់រំផ្សព្វផ្សាយដល់ប្រជាកសិករអំពីវិធីសាស្ត្រថែរក្សាគោ ក្របី ផ្តល់ទឹក ចំណី ការអនុវត្តអនាម័យល្អ និងការតាមដានអនាម័យសត្វ និងរាយការណ៍អំពីសត្វឈឺមកមន្ត្រីជំនាញផលិតកម្ម និងបសុព្យាបាល ឬភ្នាក់ងារសុខភាពសត្វភូមិ ឬអាជ្ញាធរមូលដ្ឋានដែលនៅជិតបំផុត

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- ត្រូវរាយការណ៍អំពីវឌ្ឍនភាព និងការប្រឈមបានទាន់ពេលវេលា។

ទទួលបានសារាចរណែនាំនេះ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវសហការឱ្យបានល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់អនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ៥កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**
- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងព័ត៌មាន
- -ក្រសួងធនធានទឹក និងឧតុនិយម
- -ក្រុមប្រឹក្សាស្ដារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- -គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- -ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -រដ្ឋបាលរាជធានី ខេត្ត
- -ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- -មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
- -ឯកសារ កាលប្បវត្តិ